២១៤.

# ភ្នំឧត្តុង្គ

# *La colline d'Oudong*

- en Khmer
- en Français
- en Anglais



២១៤.
ជ៧

**Petit guide**

*édité par l'Association mutualiste du Corps Enseignant Khmer*

***1997***

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

២១៤.៥៧

# ភ្នំឧត្តុង្គ ជាភ្នំព្រះរាជទ្រព្យ

❀ ❀ ❀

# La colline d'Oudong est la propriété royale

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៤៩៨៣/២០០០

❀ ❀ ❀

# The Oudong Hill is the Royal Property

❀ ❀ ❀

សៀវភៅមគ្គុទេសក៍តូចនេះ បោះពុម្ពផ្សាយដោយ
សមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B, មហាវិថីព្រះនរោត្តមភ្នំពេញ
ទូរស័ព្ទ : (០២៣) ៧២ ១០ ៤៧

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ភ្នំឧត្តុង្គ

**ភ្នំ**ឧត្តុង្គ ជាព្រះរាជទ្រព្យនៃព្រះរាជាតាំងពីទីក្រុងលង្វែក និងទីក្រុងឧត្តុង្គ ត្រូវបានជ្រើសជារាជធានីមកម៉្លេះ ។ ភ្នំនេះជាកន្លែងសំរាប់បញ្ចុះសពនៃព្រះរាជវង្សានុវង្ស និងជាកន្លែងដែលព្រះរាជាទ្រង់ព្រះរាជានុញ្ញាតអោយសាងសង់វត្ត និងព្រះវិហារ ។

នរជនណាដែលបានស្គាល់ភ្នំឧត្តុង្គ មុនឆ្នាំ ១៩៧០ ហើយបានទៅទស្សនាភ្នំនេះជាថ្មីម្តងទៀត ក្រោយឆ្នាំ ១៩៧៩ មុខជាកើតក្តីរំជួលចិត្តឥតឧបមា ដោយបានឃើញការបំផ្លិចបំផ្លាញ ដែលមិនគួរអត់អោនបាន ។

វិហារ **អដ្ឋារស** ឬវិហារ **ព្រះធំ** និងវិហារ **ព្រះចុលនិព្វាន** ត្រូវបានបំផ្លាញដល់ឫសគល់ ។ សព្វថ្ងៃនេះ គេឃើញតែសសររាងមូលដែលមានទំហំព្រាំអោប បាក់បែកអស់ពាក់កណ្តាល ជើងកោស និងកំទេចជញ្ជាំងធ្លាក់ទៅលើដី ។ ចេតិយត្រូវបានរើកកាយរកវត្ថុមានតំលៃ ។

**គំនត់និពន្ធ**



www.budinst.gov.kh www.elibraryofcambodia.org

* * *

កាលណាយើងធ្វើដំណើរចេញពីភ្នំពេញតាមផ្លូវជាតិលេខ ៥ (ផ្លូវពីភ្នំពេញទៅបាត់ដំបង) ចំងាយ ៣៧ គីឡូម៉ែត យើងនឹងប្រទះឃើញផ្លូវចូលមួយខាងឆ្វេងដៃ ឆ្ពោះទៅទិសខាងលិច ដែលមានចាក់ជ័រកៅស៊ូយ៉ាងស្អាតស្អំ ។ បើយើងចូលតាមផ្លូវខេត្តនេះទៀតចំងាយតែ ៣ គីឡូម៉ែត្រប៉ុណ្ណោះ នឹងទៅដល់ជើងភ្នំមួយដ៏មានទេសភាពស្រស់ប្រិមប្រិយ គ្របដណ្តប់ទៅដោយព្រៃព្រឹក្សាលតាវល្លិពណ៌បៃតងស្រងាត់ នឹងមានកំពូលចេតិយ កំពូលព្រះវិហារលេចចេញផុតពីចុងព្រឹក្សាទាំងនោះផង ។ ភ្នំវែងសណ្តកទទឹងថ្ងៃនេះហើយ ដែលហៅថា «**ភ្នំព្រះរាជទ្រព្យ**» ។ សព្វថ្ងៃ ទីតាំងភ្នំនេះទាំងមូលឋិតនៅក្នុងឃុំ **ផ្សារដែក ស្រុកពញាឮ** ខេត្ត **កណ្តាល** ដ៏មានអ្នកស្រុក អ្នកភូមិរស់នៅជាហូរហែតាមដងផ្លូវចូលពីផ្លូវជាតិ ទៅនឹងតាមផ្លូវលំព័ទ្ធជុំវិញជើងភ្នំនេះផង ។ នៅជាប់នឹងជើងភ្នំខាងកើតលើផ្ទៃដីរាបធំធេងស្រឡះស្រឡំ មានវត្តមួយស្អាតបាតឈ្មោះ«**វត្តគុហ៍**» ។ ទន្ទឹមនឹងវត្តនេះ មានផ្លូវជាជណ្តើរឡើងទៅដល់ភ្នំដែលរចនាពីផែនថ្មបាយក្រៀមធ្វើជាកាំយ៉ាងទូលាយ ហើយវែងលលៃបត់បែនពេនពង់ទៅតាមសណ្ឋានដីចំណោតភ្នំ ។ ហួសពីវត្តនេះទៅជិតមួយគីឡូម៉ែតទៀតទើបផុតថ្នល់ចាក់កៅស៊ូ ។ ត្រង់ផុតថ្នល់កៅស៊ូនោះ មានជណ្តើរមួយទៀតធ្វើពីឥដ្ឋឡើងទៅលើខ្នងភ្នំដែរ ។ ប្រឡបនឹងមាត់



www.budinst.gov.kh www.elibraryofcambodia.org

ជណ្ដើរមានកុនអារាមតូចមួយដ៏មានកុដិស្អាតស្អំ នឹងមានតែព្រះសង្ឃមួយអង្គគង់នៅថែទាំរក្សាព្រះវិហារចេតិយដែលមាននៅលើខ្នងភ្នំនេះទាំងអម្បាលម៉ាន ។

**ភ្នំព្រះរាជទ្រព្យ** ! ដែលហៅថា **ភ្នំព្រះរាជទ្រព្យ** នេះ គឺសំដៅដល់តួភ្នំទាំងមូលមានទាំងវិហារ ចេតិយ ព្រៃព្រឹក្សារួមជាមួយផង ។ ហេតុដូចម្ដេចបានជាគេហៅទីភ្នំនេះទាំងមូលថាជា «**ភ្នំព្រះរាជទ្រព្យ**» ដូច្នេះ ? ត្រង់នេះយើងរកឃើញចំលើយដើម្បីជំរះការសង្ស័យនេះបានថា: ដោយទ្រង់យល់ថា ភ្នំនេះមិនខ្ពស់ពេក ហើយស្ថិតនៅក្បែរឧត្ដុងជារាជវាំងស្រាប់ ព្រះរាជាសម័យនោះ ក៏ទ្រង់ចាត់អោយសាងព្រះចេតិយធំៗ នឹងមានចំលាក់លំអឆើតឆាយសំរាប់បញ្ចុះព្រះបរមអដ្ឋិ នឹងព្រះអដ្ឋិនៃព្រះរាជវង្សានុវង្ស ដោយចាត់សាងបូជនីយស្ថានទាំងនោះដោយកំលាំងព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ។ ហេតុនេះហើយ ទើបមានសន្មតនាមថា «**ភ្នំព្រះរាជទ្រព្យ**» ។ រហូតមកដល់គ្រាសព្វថ្ងៃនេះទៀត ក៏នៅតែមានការស្ថាបនាបន្ថែម នឹងការថែរក្សាទីកន្លែងនេះយ៉ាងខ្ជាប់ខ្ជួនដោយសារកំលាំងព្រះរាជទ្រព្យដែរ ។

រីឯសណ្ឋានភ្នំនឹងទីតាំងនៃបូជនីយស្ថានទាំងឡាយនៅលើភ្នំនេះ មានរបៀបរៀបចំដូចតទៅ: ទ្រង់ទ្រាយភ្នំទាំងមូល គឺវែងសណ្ដកពីជើងទៅត្បូង ជាជួរភ្នំមួយដ៏មានកំពូលខ្ពស់ត្រដែតជាងគេបីកន្លែង ដែលយើងសន្មតក្នុងនេះជាចំណុចសំគាល់បីគឺ ក.ខ.គ រាប់ពីខាងជើងទៅ ។ ត្រង់ចំណុច «ក» ខ្ពស់ជាងគេមានជណ្ដើរធ្វើពីថ្មបាយក្រៀមពេនពង់ដែលនិយាយរួចម្ដងមកហើយ ឡើងទៅដល់លើដែលមានចេតិយធំៗបីគេហៅថា «**ចេតិយត្រៃត្រឹង្ស**» ។ កាលណាយើងឡើងតាមនេះទៅដល់ភ្វាម នឹងប្រទះចេតិយធំមួយមុនគេនៅខាងឆ្វេងដៃ ដែលជាចេតិយរបស់ព្រះករុណា **ព្រះខត្តិយកោដ្ឋ «ព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិមុនីវង្ស»** ដ៏មានក្បាច់ក្បូរស្រស់បំព្រងនៅស្អាតបាតនៅឡើយ ។ យើងឡើងតាមជណ្ដើរថ្មដែលសរសៀរតាមចំហៀងចេតិយនេះបន្តិចទៅទៀត ទើបទៅដល់ចេតិយពីរ



www.budinst.gov.kh www.elibraryofcambodia.org



ទៀតមានទំហំប៉ុនគ្នា គឺបាតក្រោមមួយជ្រុងៗមានប្រវែង ១៥ម៉ែត្រ នឹងមានរបង ដែកព័ទ្ធជុំវិញនៃចេតិយទាំងពីរនេះ បណ្តាចេតិយទាំងពីរ មួយខាងត្បូង ព្រះបាទសម្តេច **ព្រះនរោត្តម** ព្រះអង្គទ្រង់សាងឡើងនៅគ.ស ១៨៩១ ដើម្បីបញ្ចុះព្រះបរមអដ្ឋិនៃព្រះបាទសម្តេច **ព្រះអង្គឌួង** ជាព្រះវររាជបិតា ។

ចេតិយនេះមានក្បាច់ក្បូរតាមបែបចេតិយធម្មតា គ្រាន់តែមានចំលាក់ប្លែក ត្រង់កំពូលនឹងសង្វារនៃព្រហ្មមុខបួន[១] តាមបែបរចនាខ្មែរតែប៉ុណ្ណោះ ។ ចេតិយខាងជើង ក៏មានទំហំប៉ុនគ្នាដែរ ប៉ុន្តែមានឆ្លាក់ជារូបដំរីលេចក្បាលធ្មោៗឡើង ប៉ុនៗដំរីមែនទែន គេហៅថាចេតិយ (**សាមពាន់**) ចេតិយនេះ ព្រះបាទ **ជ័យ**

(១)- តាមក្បាច់រចនានៅអង្គរ គឺជាមុខលោកេស្វរៈ តែខ្មែរនិយមហៅថាមុខព្រហ្ម ។



www.budinst.gov.kh www.elibraryofcambodia.org



**ជេដ្ឋា** កសាងឡើងតាំងពីគ.ស ១៦២៣ ដើម្បីបញ្ចុះព្រះបរមអដ្ឋិនៃ**ព្រះធានស្រីសុរិយោពណ៌** ជាព្រះវររាជបិតា ។ ទិដ្ឋភាពនៅលើខ្នងភ្នំត្រង់នេះ គួរជាទីទស្សនាពន់ពេកណាស់ ព្រោះមើលទៅក្រោមឃើញផ្លូវនឹងផ្ទះអ្នកស្រុកព័ទ្ធជុំវិញភ្នំ មើលទៅខាងលិចឆ្ងាយទៅ ឃើញភ្នំស្ទុងៗនៅឆ្ងាយសន្ធឹម ខាងកើតឃើញទឹកដៃ **ទន្លេសាប** នឹងភូមិអ្នកស្រុកកំពង់លួង ខាងជើងឃើញភូមិ **ចាំចាស់** នឹងផ្សារ **ឧត្តុង្គ** នឹងខាងត្បូងឃើញថ្នល់ជាតិលេខ ៥ ទៅពីភ្នំពេញវែងលលៃដូចជាលាតសន្ធឹងពួរមួយចង្វាយ ។ នៅផុតពីខ្នងភ្នំត្រង់នេះ មានជណ្តើរមួយចុះទៅចង្កេះភ្នំខាងជើងទៀត ប្រសិនជាយើងចុះទៅតាមនេះ យើងនឹងប្រទះឃើញចេតិយតូចចំទើរពីរទៀតនៅទន្ទឹមគ្នា មួយខាងកើត មួយខាងលិច គេហៅថា «**ចេតិយទន្ទឹម**» ។ ចេតិយទន្ទឹមខាងកើតព្រះបាទសម្តេច **ព្រះអង្គចន្ទ** ទ្រង់សាងឡើងគាលពីគ.ស. ១៧៩៨ ដើម្បីបញ្ចុះព្រះអដ្ឋិនៃព្រះបាទសម្តេច **ព្រះអង្គអេង** ជាព្រះវររាជបិតា ។ សព្វថ្ងៃកំពូលបាក់ជ្រុះខ្វះទៅហើយ មួយទៀតខាងលិច គឺព្រះបាទ **ជ័យជេដ្ឋា**



www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់សាងពីគ.ស. ១៦២៣ ដើម្បីបញ្ចុះព្រ
សព្វថ្ងៃនៅប្របចេតិយនេះ មានព្រះសង្ឃគង.
ជានិវេសនដ្ឋាន ។

យើងឡើងត្រលប់ទៅកាន់ចេតិយ **ទៃ្រត្រ័ឝ្រ** ត្រង់ចំណុច «ក» វិញ រួច យើងចុះទៅតាមជណ្តើរដដែល ទៅខាងត្បូងអែបតាមចេតិយនៃព្រះករុណាព្រះ **ខត្តិយកោដ្ឋ** ហើយយើងមិនចុះជណ្តើរវែងមក កាន់ដីរាបវិញនៅឡើយទេ យើង ដើរឆ្ពោះទៅត្បូងត្រង់ ។ យើងចុះជណ្តើរស៊ីម៉ង់ត៍បន្តិច យើងដើរលើដីទទេ តែ ដីត្រង់នេះមិនរាបស្មើទេ ចេះតែសំយុងចុះបន្តិចម្តងៗ ហាក់ដូចជានាំដំណើរយើង អោយចុះទៅកាន់ជ្រោះជ្រលងភ្នំ លើថ្មរកិបរកុបពុំរាបស្មើ ដំបូងយើងប្រទះ គុហាតំរៀបជញ្ជាំងថ្មបាយក្រៀមតូចមួយ មានដំកល់ព្រះពុទ្ធរូបមួយអង្គ គេ ហៅថា **ព្រះពុទ្ធរូបម្លូកតាដំបងដែក** ។ យើងសរសៀរតាមចំហៀងខាងកើតនៃ គុហានេះយ៉ាងពិបាក ព្រោះផ្លូវចង្អៀតឆ្លងកាត់ក្បាលថ្មដ៏ខ្ពស់ៗ ហើយធំៗផង ។ ទៅមុខបន្តិចទៀត ដីកាន់តែចោតជ្រៅទៅ ឆ្លងកាត់ជ្រលងនេះរួច ប្រទះឃើញ មានគុហាតូចៗបីទៀត នៅជង្ហួរជង្ហែពីជើងទៅត្បូង ។ ដំបូងជាគុហាចាស់ធ្វើពី ឥដ្ឋសឹងតែរបេះចេញពីគ្នាទៅហើយ គុហានេះគេហៅថា «**ព្រះនាគ**» គឺដំកល់ ព្រះពុទ្ធរូបនាគប្រក់ ។ តទៅទៀតគុហា «**ព្រះកែច**» មានទំហំតូចជាងមុន គឺដំកល់ព្រះពុទ្ធរូបតូចល្មមមួយព្រះអង្គទៀត ។ នៅខាងត្បូងគេគឺ «**គុហាព្រះ គោ**» ដ៏ជាគុហាតូចទាបរងញ៉ាបសឹងតែត្រឹមក្បាលមនុស្ស គ្របពីលើរូបគោមួយ ដេកនៅលើអាសនៈបែរមុខទៅអគ្នេយ៍ ។ ផុតពីនេះ ផ្ទៃដីខ្វុងជ្រៅថែមទៅទៀត ។ ត្រង់ទីទំនាបនោះ មានជណ្តើរមួយចុះទៅផ្ទៃដីរាបងផ្លូវថ្នល់នឹងមានជណ្តើរមួយ ទៀត ឡើងទៅកាន់ដីខ្នងភ្នំទួលខ្ពស់មួយកន្លែងទៀតជាចំណុច «ខ» ។ ត្រង់ចំណុច «ខ» នេះ មានព្រះវិហារមួយធំជាងគេ ក្នុងបណ្តាបូជនីយស្ថានទាំងឡាយនៅភ្នំ



www.budinst.gov.kh www.elibraryofcambodia.org



**ព្រះរាជទ្រព្យ** គឺមានទំហំបណ្តោយ ៤០ ម៉ែត្រ នឹងទទឹង ២៣,៤០ម បែរមុខឆ្ពោះមកទិសខាងជើង គឺចំផ្លូវដើរមកពីជើងដែលយើងរាប់រៀបហូរហែមកហើយនោះ ។ បើយើងឈរមើលពីដីទំនាប មាត់ជណ្តើរខាងមុខ មុននឹងឡើងទៅកាន់ព្រះវិហារនេះ យើងនឹងឃើញទិដ្ឋភាពវិហារខ្ពស់ត្រដែតលេចចេញពីចុងឈើខ្នាន់ខ្នាប់ ។

ព្រះវិហារនេះមានភាពចំលែកណាស់ បើយើងធៀបផ្ទឹមនឹងវិហារនានាទាំងអស់ក្នុងប្រទេសកម្ពុជា គឺទីមួយត្រង់បែរមុខឆ្ពោះទៅទិសខាងជើង ប្លែកពីព្រះវិហារទាំងឡាយដែលតែងតែបែរទៅខាងកើត ទីពីរត្រង់ដំបូលព្រះវិហារនេះពុំមានសណ្ឋានខ្ពស់ស្រួចងទន្ទាំប្រកបដោយជហ្វាដងក្តារដូចវិហារនានាទេ គឺបែរជារាងទាបទទាមានសណ្ឋានប្រហែលដំបូលផ្ទះប៉ិតទៅវិញ ។ ជញ្ជាំងព្រះវិហារធ្វើពីឥដ្ឋបូកបាយអយ៉ាងក្រាស់ ខាងក្នុងមានសសរចំនួន ២៦ ចែកជាបួនជួរបណ្តោយព្រះវិហារ ។ ពីរជួរជើងរៀងចំហៀងម្ខាង ៧ នឹងជើងរៀងមុខពីរ មានទំហំ ០,៦០ម ឯពីរជួរកណ្តាលជាកន្លោងសសរនីមួយៗ មានទំហំ ២ម បើមនុស្ស



www.budinst.gov.kh www.elibraryofcambodia.org

ឈរកាងដៃបន្តគ្នា ៥នាក់ ទើបអោបសសរនេះជុំ ។ នៅក្នុងព្រះវិហារនេះទៀត មានព្រះពុទ្ធរូប **មារទិជ័យ** មួយព្រះអង្គធំសំបើម គ្រាន់តែទទឹងភ្នែនពីចុងម្ខាង ទៅចុងម្ខាង ១០ម កំពស់ពីបល្ល័ង្កទៅដល់ចុងម្លី ១១,៤០ម ហេតុនេះហើយ





www.budinst.gov.kh www.elibraryofcambodia.org

បានជាចុងម្លីត្រូវខ្ពស់ទុលទៅដល់ដំបូលព្រះវិហារ បើគិតកំពស់នេះទៅនឹងខ្នាតបុរាណ ដែលនិយមរាប់ហត្ថព្រះសុគតសំរាប់វិន័យក្នុងព្រះពុទ្ធសាសនានោះឃើញថា មានកំពស់ ១៨ ហត្ថព្រះសុគតនេះឯង ។ អាស្រ័យដោយព្រះពុទ្ធរូបដ៏ធំអស្ចារ្យមានកំពស់ដល់១៨ ហត្ថយ៉ាងនេះហើយ ទើបអ្នកស្រុកសន្មតនាមព្រះវិហារនេះថា «**វិហារអដ្ឋារស**» មានន័យថា ដប់ប្រាំបី គឺសំដៅដល់ព្រះពុទ្ធរូបគង់កំពស់ ១៨ហត្ថ ។ រីឯការប្លែកគួរអោយឆ្ងល់ត្រង់បែរមុខទៅជើង នឹងមានដំបូលទទានោះ បើតាមឯកសារនៅក្រុមជំនុំទំនៀមទំលាប់ស្តីអំពីប្រវត្តិព្រះវិហារនេះថា កាលពីរវាងសតវត្សទី ១៣ ឯនោះ ចិនបានមកស្ថាបនាព្រះពុទ្ធរូបនេះឡើង ហើយធ្វើជាដំបូលប្រក់ឃុំគ្រងរក្សាព្រះពុទ្ធរូបនេះផង ។ ដូច្នេះ ចិនក៏រចនាដំបូលទាបទទាតាមរចនាចិន ហើយដំកល់ព្រះពុទ្ធរូបអោយបែរព្រះភក្ត្រទៅខាងជើង ឆ្ពោះទៅកាន់ប្រទេស **ចិន** តាំងពីកាលដំបូងនោះមក ។ អាស្រ័យលើគំនិតថែទាំទុកដំណែលដើម ព្រះរាជាខ្មែរយើងក៏ព្រះអង្គពុំកែប្រែអោយបាត់ផានឡើយ ទោះបីជាព្រះអង្គបានជួសជុលឬសាងបន្ថែមនូវវត្ថុព្រះវិហារនេះ មួយលើកពីរលើកមកហើយក៏ដោយ ។

ផុតអំពីព្រះវិហារនេះទៅ យើងពុំអាចដើរលើខ្នងភ្នំនេះបណ្តាយទៅមុខទៀតកើតទេ ស្បិតព្រៃផ្សេស្មុគស្មាញពេក ដូចនេះ យើងត្រូវចុះថយមកដល់ដីរាបធម្មតាសិន រួចទើបឡើងទៅខ្នងភ្នំខាងកើតដែលជាភ្នំតែមួយដដែល ប៉ុន្តែ ពេនបត់មកខាងកើតវិញ មានសណ្ឋានដូចមករឬក្រពើត្រកងកន្ទុយ ឬវាត់កន្ទុយពីក្រោយមកមុខវិញ ។ ខ្នងភ្នំនេះជាចំណុច «គ» ដែលមានជណ្តើរដីធម្មជាតិ នឹងមានតំរៀបដុំថ្មគ្រាន់តែកុំអោយរអិល នៅពេលមានភ្លៀងប៉ុណ្ណោះ ។ យើងដើរឡើងតាមជណ្តើរនេះ មិនខ្ពស់ជាងត្រង់ចំណុច «ខ» ទេ យើងនឹងប្រទះឃើញផ្លូវបែកជាពីរត្រង់ មានស្រះជាអាងទឹកមួយនៅកណ្តាល គឺខាងស្តាំដៃបែកឡើងទៅ



www.budinst.gov.kh www.elibraryofcambodia.org

កាន់វិហារមួយតូចល្មម រៀបចំបែប **ខ្មែរឥស្លាម** គេហៅថាវិហារ **តាសាន់** សង់ពីបាយអប្រក់គ្បឿង ។ ឯខាងឆ្វេងបែកទៅកាន់ «**ព្រះវិហារព្រះនិព្វាន**» ដ៏មានដំបូលប៉ិតប្រក់គ្បឿងយ៉ាងចាស់ ជញ្ជាំងធ្វើពីបាយអយ៉ាងក្រាស់ តែចាស់ជ្រៅបន្តិចទៅហើយ ។ ព្រះវិហារនេះបែរមុខទៅជើងដែរ មានទទឹង ៨ម បណ្តោយ ១១,២០ម ហើយនៅក្នុងនោះមានព្រះពុទ្ធរូប **បរិនិព្វាន** មួយព្រះអង្គ ព្រះកេសទៅកើត ព្រះបាទទៅខាងលិច បែរព្រះភក្ត្រទៅខាងត្បូង បណ្តោយព្រះអង្គពីព្រះកេសទៅដល់ចុងព្រះបាទប្រវែង ១០ម៉ែត្រ ។ នៅពីមុខជាប់នឹងព្រះវិហារនេះមានចេតិយចាស់ជរាមួយដែលកសាងឡើងតាំងពី គ.ស. ១៥៦៧ គឺព្រះបាទ **បរមិន្ទរាជា** ទ្រង់សាងសំរាប់បញ្ចុះព្រះអដ្ឋិនៃព្រះបាទ **ចន្ទរាជា** ជាព្រះវររាជបិតា ។

កាលណាយើងចុះពីខ្ពង់រាបនេះមកកាន់ដីទំនាបៗធម្មតា យើងនឹងប្រទះឃើញចេតិយតូច-ធំចាស់ៗជាច្រើនដេរដាស ខ្លះរុះធ្លាក់បាយអនឹងឥដ្ឋរដាច់រដោចនឹងមានដើមឈើដុះគ្របពីលើ តែមានខ្លះទៀតនៅគង់វង់ល្អនៅឡើយ ។ ចេតិយទាំងនេះ ជារបស់ព្រះរាជានឹងព្រះរាជវង្សានុវង្សពីមុនៗមក ។

ដូចនេះ សរុបសេចក្តីបានដូចតទៅ គឺឈ្មោះភ្នំដែលហៅថា «**ភ្នំព្រះរាជទ្រព្យ**» នោះ ដោយសារជាទីដែលព្រះរាជាតាំងពីដើមមក ទ្រង់ទុកជាបូជនីយស្ថានផ្ទាល់ព្រះអង្គ នឹងរាជវង្សានុវង្សព្រះអង្គផង ដូចមានការរាប់រៀបពីចេតិយនីមួយៗ ដែលជាសំខាន់ៗជាងគេនៅលើភ្នំនេះរួចមកហើយស្រាប់ ។ ឯឈ្មោះព្រះវិហារថា «**វិហារអដ្ឋារស**» នោះគឺសំដៅដល់ព្រះវិហារដែលមានដំកល់ព្រះពុទ្ធរូបកំពស់ ១៨ ហត្ថនោះឯង ។

* * *



www.budinst.gov.kh www.elibraryofcambodia.org

# សញ្ញាសំគាល់

* * * *

1 ចេតិយ **សាមពាន់** (ព្រះបាទ **ជ័យជេដ្ឋា**
សាងពី គ.ស. ១៦២៣)

2 ចេតិយព្រះបាទ **នរោត្តម**
សាងពី គ.ស. ១៨៩១ ។

3 ចេតិយព្រះករុណាខត្តិយ
(**ព្រះមុនីចន្ទ**) សាងពី គ.ស...។

4 ព្រះវិហារ **អង្គារស**

5 ព្រះវិហារ **ព្រះនិព្វាន**

6 ចេតិយព្រះបាទ **បរមិន្ទរាជា**
(សាងពី គ.ស. ១៥៦៧ )

7 វិហារពួក **តាសាន់** (ខ្មែរ **ឥស្លាម** កាន់សីលប្រាំ )

8 ចេតិយ **ឧទ្ទឹម** (ខាងកើតព្រះបាទ **អង្គចន្ទ**
សាងពី គ.ស. ១៧៩៨ )

9 ចេតិយ **ឧទ្ទឹម** (ខាងលិចព្រះ **ជ័យជេដ្ឋា**
សាងពី ១៦២៣)

10 គុហាអ្នកតា **ដំបងដែក**

11 គុហា **ព្រះនាគ** (ពុទ្ធរូប **នាគប្រក់**)

12 គុហា **ព្រះកែវ** ( ព្រះពុទ្ធរូប )

13 គុហារ **ព្រះគោ** (រូបគោដេក)






www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# La colline d'Oudong

LIBRARY
BUDDHIST INSTITUTE

*La colline d'Oudong est la propriété privée du Roi depuis que Lovêk et Oudong ont été choisis comme capitales du Royaume. Elle était le lieu d'inhumation des membres de la famille royale et aussi le lieu où le Roi faisait construire des monastères et des temples.*

*Ceux qui ont connu la colline avant 1970 et l'ont visitée de nouveau après 1979 ont ressenti sans doute une très vive émotion en constatant les actes de vandalisme impardonnables.*

*Le temple " Attharas " ou le temple du Grand Bouddha et le temple du Bouddha couché ont été complètement détruits. On ne voit aujourd'hui que les piliers de forme cylindrique de cinq brassées à moitié brisés, le soubassement et des débris des pans de mur tombés par terre. Les stupàs ont été fouillés pour y chercher des objets précieux.*

***Note de la rédaction.***



www.budinst.gov.kh www.elibraryofcambodia.org

* * *

Si l'on prend la R.N.5 pour se rendre à Battambang, on voit, à 37 Km de Phnom Penh, à gauche, une route conduisant, à l'ouest vers une colline verdoyante que surmontent les stupàs des rois dominant la végétation luxuriante. La colline d'Oudong s'étendant du Nord au Sud s'appelle aussi la colline "Preah Réach Trâp" [(1)]. Elle est situeé dans la commune de Phsar Dèk, district de Ponhea Lu province de Kandal. De chaque côté de la route menant à la colline, et sur le bord de la route qui fait le tour de la colline, des maisons d'habitation sont bâties côte à côte. A l'Est, au pied de la colline et sur un grand terrain bien aplani, est construite une pagode appeleé Wat Kuh. A côté de cette pagode, un escalier dont les larges marches sont en granit serpente en suivant la pente de la colline. Au bout de la route, un autre escalier dont les marches sont en brique mène aussi au sommet du Phnom ( colline ). Au pied de l'escalier est érigée la petite maison bien propre du bonze qui assure la garde de tous les stupas du Phnom.

---

(1)- domaine de la royauté.



www.budinst.gov.kh www.elibraryofcambodia.org

Le Phnom Preah Reach Trap est ainsi nommé parce que ce Phnom, d'une altitude moyenne, est choisi par de Roi résidant à Oudong pour y faire construire les stupàs des rois et ceux de la famille royale.

La colline, de forme allongée a trois sommets bien distincts: sommets A.B.C comptés du Nord du Sud. Le point A, le plus élevé que les autres a un escalier aux marches en granit dont nous venons de parler. Cet escalier nous conduit aux trois grands stupàs appelés "Chédei Trei Treng". Quand on arrive au sommet de l'escalier, on voit d'abord à gauche un grand stupàs orné de fines ciselures. C'est le stupàs de Preah Sisowath Monivong. En suivant l'escalier qui longe ce stupa, on voit deux stupàs ayant la même taille dont la base de 15m de côté est entourée d'une clôture en fer. Le stupà qui est au Sud est celui que le Roi Norodom a fait construire en 1891 pour y inhumer les cendres de son père, Preah Bat Samdech Ang Duong. Ce stupà a des ciselures comme les autres stupàs mais celles du sommet et des cordons portés en sautoir par le Brahma à quatre faces sont distinctes. Le stupà au Nord aux ciselures en forme d'éléphant dont la tête est de grandeur naturelle. C'est le Chédei Sampean. Il a été construit en 1623 par Preah Bat Chey Chettha pour y inhuner les cendres de Preah Bat Srey Soriyopor, son père. A cet endroit, on découvre un panorama splendide: la route contournant le Phnom et les maisons des habitants. Au loin à l'ouest les montagnes enveloppées de nuages. A l'Est, le Tonlé Sap et les villages de Kompong Luong. Au Nord, le hameau Veaing Chas et le marché d'Oudong. Au Sud la R N 5 s'étend comme une longue corde sur la terre. D'ici, si l'on descend un petit éscalier qui va vers l'extrémité Nord de la colline, on découvre deux stupàs de taille moyenne qui sont



www.budinst.gov.kh www.elibraryofcambodia.org

côte à côte, l'un à l'est, l'autre à l'ouest. On les appelle "Chédei Tontim". Le stupà à l'est construit en 1798 par Preah Bat samdach Preah Ang Chan pour y inhumer les cendres de Preah Bat Samdach Preah Ang Eng, son père. Actuellement le sommet du stupà est cassé, le stupa, à l'ouest, a été construit en 1623 par Preah Bat Chettha pour y inhumer les cendres de Préah Satha, son oncle. A côté de ce stupà sont construits de petits " Kot" pour servir de résidence aux bonzes.

Si l'on retourne aux Chédei Trey Treng (point A) en longeant le même escalier pour aller vers le Sud sans le descendre jusqu'au pied de la colline, on découvre une sorte de petite caverne dont les murs sont en granit. Elle abrite la statue du génie tutélaire appelé Nak Ta Dambang Dêk. En continuant notre marche en suivant le chemin étroit et rocailleux, on découvre trois petites cavernes : la caverne de Preah Neak qui est une statue de Bouddha assis sur le Naga, la plus petite caverne très basse de Preah Kèo et au Sud la caverne de Preah Ko abritant la statue d'un bœuf couché sur un socle, la tête tournée vers le Nord Est.

A partir de cela, la chemin descend de plus en plus bas et à cet endroit il y a un autre escalier. Au sommet du point B est construit un temple monumental par rapport aux autres constructions bâties sur ce Phnom Preah Reach Trap. Il a 40m de long et 23,40m de large et s'oriente vers le Nord. Si l'on reste debout sur le terrain plat et l'on regarde le temple, on voit qu'il domine la végétation verdoyante.

Ce temple a un aspect étrange si on le compare avec les autres temples du Royaume. D'abord, il s'oriente vers le Nord, ce qui n'est pas conforme aux principes généraux admis que



www.budinst.gov.kh www.elibraryofcambodia.org

tous les temples se tournent vers l'Est. Ensuite, la toiture n'est pas haute et n'a pas d'ornement architectural en forme releveé. Elle ressemble plutôt à celle de maison au toit à quatre pans. Les murs sont en briques couverts d'épais mortier. Les vingt six



piliers cylindriques rangés suivant la longueur du temple ont les uns 0,60m de diamétre et les autres 2m. Cinq personnes pourraient l'étreindre. Une colossale statue de Bouddha "Màravijay" trône au fond du temple, les jambes croisées. L'écart entre les deux genoux est de 10m. Du piédestal au chignon, le corps du Bouddha mesure 11,40m. Ce qui fait que le chignon touche le plafond. Si l'on prend l'unité de mesure ancienne utilisée dans la tradition religieuse du Maître, la statue a une hauteur de 18 coudées de Bouddha. C'est pour cette raison que les fidèles nomment ce temple Attharas qui signifie 18 coudeés. En outre, ce temple est caractéristique en ce sens qu'il s'oriente vers le Nord et qu'il a une toiture particulière. Le document de la commission des mœurs et coutumes parlant de l'historique de ce temple dit qu'au 13e siècle, les Chinois ont construit ce



www.budinst.gov.kh www.elibraryofcambodia.org

grand temple abritant une énorme statue de Bouddha. Les Rois Khmers, dans l'esprit conservateur et tolérant, ont gardé tout ce qu'ont laissé les Chinois.



A partir de ce temple, il n'y a pas de chemin qui conduit à l'éxtrémité Est de la colline. On doit descendre l'escalier se trouvant en face pour se diriger vers un autre escalier en brique qui mène vers une mosqueé n'ayant pas de dôme, appeleé " Vihéa Ta Sann " Celle-ci est en maçonnerie et recouverte de



www.budinst.gov.kh www.elibraryofcambodia.org

tuiles. A gauche, un temple actuellement détruit de fond en comble s'oriente aussi vers le Nord. Il mesure 11,20m de long et 8m de large et abrite une gigantesque statue de Bouddha couché d'une longueur de 10 mêtres. La tête tourneé vers l'Est et le



visage tourné vers le Sud. En face de ce temple, un vieux stupà a été construit en 1567 par Preah Bat Boromintho Réachéa pour l'inhumation des cendres de Preah Bat Chan Reacha, son père.

A la descente du ( point C) par le mêne escalier on découvre de petits et de grands stupàs par-ci et par là tombant en ruine sous des arbres ou restant en bon état. Ce sont des stupàs des membres de la famille royale.



www.budinst.gov.kh www.elibraryofcambodia.org

En conclusion, est appelé Phnom Preah Reach Trap, parce qu'il est le lieu de pélerinage du Roi et de sa famille. Quant au " Vihea Attharas", il est ainsi nommé parce qu'il abrite une statue de Bouddha qui mesure 18 coudeés du Maître.

*Adapté du texte Khmer écrit en 1963*





www.budinst.gov.kh www.elibraryofcambodia.org

# Légende

* * *

1 Stupa sampean (Preah Bat Chey Chettha construit en 1623)

2 Stupa Preah Bat Norodom, construit en 1891

3 Stupa Preah Monivong, construit en.............

4 Vihea Preah Attharas

5 Vihea du Bouddha couché (entré au Nirvana)

6 Stupa Preah Bat Borominthoreachea, construit en 1567

7 Vihea Ta Sann (Khmer Islam pratiquant les Pancha Sila)

8 Stupas accouplés (à l'Est, celui de Preah Bat Ang Chan, construit en 1798)

9 Stupas accouplés (à l'Ouest, celui de Preah Bat chey Chettha, construit en 1623)

10 Caverne du Génie Ta Dambang Dêk

11 Caverne du Bouddha assis sur le Naga

12 Caverne du Bouddha Preah Kèo

13 Caverne de Preah Ko (statue du bœof couché)






www.budinst.gov.kh www.elibraryofcambodia.org

# Oudong Hill

*Oudong Hill is the private property of the King since Lovek and Oudong were chosen as capitals of the Kingdom. It was the location for burial of the royal family and also the location where the king had constructed monasteries and temples.*

*Those who knew the hill before 1970 and have visited since 1979 have, no doubt, felt a strong shock on seeing the unpardonable vandalism.*

*The temple "Attharas" or the temple of the Grand Buddha and the temple of the Sleeping Buddha were completely destroyed. Today, one only sees the five cylindrical support pillars, half broken, the sub-basement and the debris of the broken walls fallen to the ground. The stupas have been scattered in search of precious articles.*



www.budinst.gov.kh www.elibraryofcambodia.org

⁂ ⁂ ⁂

If one takes National Road 5 toward Battambang, one sees on the left, at kilometer 37 from Phnom Penh, a road running off to the west towards a green hill which rises to the stupas of kings dominating the lush vegetation. Oudong Hill extending from north to south is also called " Preah Reach Trap ". It is situated in the commune of Phsar Dek, the district of Ponhea Lu, in the province of Kandal. On each side of the road leading to the hill, and on the side of the road which circles the hill, houses are constructed side by side. On the flattened terrain at the eastern foot of Oudong is constructed a pagoda called Wat Kuh. Next to this pagoda a stairway with large steps of granite snakes its way up the slope of the hill. At the end of this stairway another stairway of brick steps leads to the summit of the Phnom (hill). At the foot of these steps is located the neat little house of bronze standing guard over all of the stupas of the hill.

Phnom Preah Reach Trap is so named because this Phnom, of modest height, was chosen by the resident king at Oudong to make the king's stupas and those of the royal family.

The hill is formed along three distinct summits : summit A, B & C running north to south. Summit A is the highest and has a granite stairway which was mentioned above. This stairway



www.budinst.gov.kh www.elibraryofcambodia.org

leads to three large stupas called " Chedei Trei Treng ". On



arriving at the top one first sees, to the left, a large stupa ornamented with delicate carvings. This is the stupas of " Preah Sisowath Monivong ". On following the stairs which run to this stupas one sees two additional stupas of equal height with bases of 15 meters and enclosed with an iron railing. The one to the south is that which King Norodom had constructed in 1891 for the burial of his father, Preah Bat Samdech Ang Doung. This stupas has fine carving as the others, but those of the summit wearing strands around the neck of the four faced Brahma are distinctive. The stupas to the north with a carved elephant has a life-sized head. This is the " Chedei Sampean " and was constructed in 1623 by Preah Bat Chey Chettha for burial of the ashes of Preah Bat Srey Soriyopor, his father. In this location one discovers a splendid view: the road leading to Phnom Penh and many residences. Off to the west the mountains surrounded



www.budinst.gov.kh www.elibraryofcambodia.org

with clouds. To the east, the Tonle Sap river and the villages of Kompong Luong province. To the north, the hamlet Veaing Chas and the markets of Oudong. And to the South Route 5 extends like a long cord on the land. From here, if one descends a small stairway which runs toward the north of the hill, one discovers two more stupas of medium height standing side by side : one to the east--one to the west. They are called " Chedei Tontim ". The stupas to the east was constructed in 1798 by Preah Bat Samdech Preah Ang Chan built for the ashes of Preah Bat Samdech Preah Ang Eng, his father.. Today, the summit of the stupas is broken. The stupas to the west was constructed in 1623 by Preah Bat Chettha for burial of the ashes of his uncle, Preah Satha. On the side of this stupa stand the little " Kot" to serve the residences in bronze.





www.budinst.gov.kh www.elibraryofcambodia.org

Returning to Chedei Trey Treng (point A) along the same stairway running to the south without descending to the foot of the hill, you discover a small cavern with walls of granite. It houses the statue of the guardian genie called Nak Ta Dambang Dek. Continuing your walk on the same narrow rock path, you discover three little caverns: the cavern of Preah Neak with the Buddha seated on the Naga; the smallest cavern at the lowest point of Preah Keo and to the south the cavern of Preah Ko housing the statue of a cow sitting on pedestal, its head turned to the north-east.

Apart from that the path descends lower and lower and at that point there is another stairway. At the summit of point B is a monumental temple as compared to the others built on the Phnom Preah Reach Trap. It is 40 meters long and 23.4 meters wide and faces the north. If one stands on the flat ground and look at the temple, one sees that it dominates the surrounding green vegetation.

This temple has a strange aspect if you compare it with the others of the kingdom. First, it faces north, which doesn't conform to the general principle that all temples face to the east. Next, the roof is not high and does not have the standard relief architecture. Rather it resembles that of a house with a four cornered roof. The walls are of brick covered with thick mortar. The twenty six round pillars arranged along the length of the temple are of. 60 meters while others are 2 meters. Five people could encircle them. A colossal statue of Buddha, " Maravijay ", sits on a throne at the back of the temple, legs crossed. The distance between the two knees is 10 meters. From the pedestal to the Buddha's coil of hair, almost touching the ceiling, measures 11.4 meters pedestal. If one uses the ancient



www.budinst.gov.kh www.elibraryofcambodia.org



unit of measurement used by the masters of statuary in religious art, this is an 18 cubit Buddha. It is for this reason that the fidel call this monument "Attharas" which signifies 18 cubits. Otherwise, this temple is characterized by the fact that it faces north and by its unique roof. The document recorded by the commission on mores and customs discusses the history of this 13th century temple being built by the Chinese and housing an enormous Buddha. The Khmers kings, in the spirit of conservation and tolerance, kept all that was left by the Chinese.



www.budinst.gov.kh www.elibraryofcambodia.org

From this temple there is no path that leads to the eastern part of the of the hill. One must descend the facing stairway and leading to a brick stairway which leads to a mosque having no dome, called " Vihea Ta Sann ". This structure is built of masonry and overlaid with tiles. To the left, a temple, today completely destroyed to its foundation, also faces to the north. It measures 11.2 meters long by 8 meters wide and houses a large sitting Buddha of a height of 10 meters : head turned to the east and facing the south. In front of this temple an old stupa was constructed in 1567 by Preah Bat Boromintho Reachea for burial of the ashes of Preah Bat Chan Reacha, his father.

On descending the same stairs one discovers some small and large stupas here and there fallen in ruin under the trees or remaining in good condition. These are the stupas of the members of the royal family.

In conclusion, Phnom Preah Reach Trap, named because it was the place of pilgrimage of the king and his family. As for Vihea Attharas, it was likewise named because of the Buddha measuring 18 cubits........in the master's measure.

*Adapted from the Khmer text of 1963*
*Translated from French by John KATT*



www.budinst.gov.kh www.elibraryofcambodia.org

$ 1.00

ពុម្ព មន្ត្រីមាស
ENTRY MEAS PRINTING HOUSE

www.budinst.gov.kh www.elibraryofcambodia.org